ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៥៨/២៦ ន.ដ.ក

# របាយការណ៍
## ស្តីពី
## ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
## ប្រចាំខែកុម្ភៈ និងទិសដៅខែមីនា ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្សជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងខែកុម្ភៈនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ,ជ,ប,ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ២២,៨០២លើក មានអ្នកចូលរួមសរុបចំនួន ១,១២០,១៦៣នាក់ ក្នុងនោះស្ត្រី ៥៩៩,៣០៥នាក់ (ប្រៀបធៀបនឹងខែមករា មានចំនួន ៨១៩,៨៤១នាក់) កើនឡើង ៣០០,៣២២នាក់ ស្មើនឹង ៣៦,៦៣% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត (ថ្នាក់ជាតិ) | ០១ | ២,៥០០ | ៧៥០ |
| | -រាជធានីភ្នំពេញ(វិ.ជម្លូវន្ត, វិ.ភ្នំពេញថ្មី, សាលា AIS) | ១០ | ១,៧៤៨ | ១,០៥៤ |
| | -ខេត្តកំពង់ចាម | ០១ | ៧៥០ | ៥៨៤ |
| | -ខេត្តក្រចេះ | ០១ | ៥៥០ | ២១៨ |
| ២ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២៥ | ០១ | ២,៩០០ | ៨៧៩ |
| | -ខេត្តស្វាយរៀង | ០១ | ៤៥០ | ១៩៣ |
| ៣ | ច្បាប់ វេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | ២២,៧២៨ | ១,១០០,៦១៨ | ៥៨៩,០៦៤ |
| ៤ | កម្មវិធីផ្សេងៗ | ៥៩ | ១០,៦៤៧ | ៦,៥៦៣ |
| | សរុប | ២២,៨០២ | ១,១២០,១៦៣ | ៥៩៩,៣០៥ |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតឡើយ)*

❖ **យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត**

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហជាមួយ ក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហភាពសហព័ន្ធយុវជនកម្ពុជា និងគាំទ្របច្ចេកទេសដោយក្រុមហ៊ុន Smart Axiata មូលនិធិ CBRD Fund អង្គការ APLE, Mission Alliance, Child Fund, Auscam, HAGAR, MARICI, អង្គការម្លប់តាប៉ាង បានប្រារព្ធកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ដោយមានអ្នកចូលរួមសរុបប្រមាណ ២,៥០០នាក់ ស្រី ៧៥០នាក់។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយ រដ្ឋបាលខេត្តកំពង់ចាម ខេត្តក្រចេះ វិទ្យាល័យជម្លូវ័ន្ត វិទ្យាល័យភ្នំពេញថ្មី សាលាអន្តរជាតិ AIS នៅរាជធានីភ្នំពេញ និងគាំទ្របច្ចេកទេស ដោយក្រុមហ៊ុន Smart Axiata និងអង្គការ APLE, Child Fund បានប្រារព្ធកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ **«ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ»** ចំនួន **១២លើក** ដោយមានការអញ្ជើញចូលរួមជាអធិបតី លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ និងសិស្ស សរុបប្រមាណ ៣,០៤៨នាក់ ស្រី ១,៨៥៦នាក់។

❖ **ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សហការជាមួយ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ និងគាំទ្របច្ចេកទេសដោយអង្គការ ERIKS, សម្ព័ន្ធចាប់ដៃ, AIM, IJM, HAGAR, DAI CAMBODIA, CPU និង MARICI បានប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ,ជ,ប,ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ ដោយមានការអញ្ជើញចូលរួមពី តំណាងព្រះពុទ្ធសាសនាទាំងពីរ គណៈតំណាងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា សមាជិករាជរដ្ឋាភិបាល រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងរាជបណ្ឌិត្យសភាកម្ពុជា អភិបាល អភិបាលរង ស្នងការ ស្នងការរង រាជធានី ខេត្ត តំណាងសាសនាធំៗទាំងបី តំណាងស្ថានទូត ស្ថានតំណាង ប្រចាំនៅព្រះរាជណាចក្រកម្ពុជា កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត សហភាពសហព័ន្ធយុវជនកម្ពុជា យុវជនកាយឫទ្ធិ យុវជនកាកបាទក្រហម វិស័យឯកជន ព្រមទាំងអង្គការដៃគូ សរុបប្រមាណ ២,៩០០រូប ស្រី ៨៧៩រូប ។

▪ **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំពិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ក្រោមប្រធានបទ"រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" វត្តមានចូលរួមចំនួន ៤៥០នាក់ ស្រី ១៩៣នាក់។

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នា តាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ២២,៧២៨លើក មានអ្នកចូលរួមសរុបចំនួន ១,១០០,៦១៨នាក់ ក្នុងនោះស្ត្រីចំនួន ៥៨៩,០៦៤នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| តារាងទិន្នន័យវេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ/ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៨១ | ២១,៤៨៦ | ១០,៥៣២ | ២៣ | ១,៥៥២ | ៨៣១ |
| ២ | ខេត្តកណ្តាល | ២,៧១២ | ១៦៦,៧៧៥ | ៨៨,៧៦២ | ៨៤៦ | ៤៩,៥៩៧ | ២២,០៨៣ |
| ៣ | ខេត្តបាត់ដំបង | ៩៤៩ | ៤៥,៧០១ | ២៥,៦២៦ | ៧៧៣ | ២៦,៥១២ | ១៤,៨៤១ |
| ៤ | ខេត្តពោធិ៍សាត់ | ៦១៤ | ៤១,៨៤៧ | ២១,៨៨១ | ៣៤៩ | ១៣,២០៦ | ៦,៦២២ |
| ៥ | ខេត្តសៀមរាប | ១,១៤០ | ៨៥,១៥៥ | ៥២,៤២៩ | ៩៨៦ | ៣៥,៤៩៦ | ២៣,៤៧៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧៧៩ | ២៨,១៨៣ | ១៣,៧៦៥ | ៦០១ | ១៦,១៥៥ | ៨,១៦២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | ខេត្តកំពង់ចាម | ១,៨៣៣ | ១១៦,១៧៤ | ៥៦,៥៧១ | ១,០៤៥ | ៤៤,៥៥៨ | ២៥,០៤៩ |
| ៨ | ខេត្តព្រះសីហនុ | ១៦ | ៦១៥ | ៣០១ | | | |
| ៩ | ខេត្តព្រះវិហារ | ០១ | ២៦ | ២៤ | | | |
| ១០ | ខេត្តស្វាយរៀង | ៣៤៨ | ១៨,៤៧៥ | ១០,៥៨៧ | ៤៨៧ | ១៧,៩៣៥ | ៩,៥១៥ |
| ១១ | ខេត្តប៉ៃលិន | | | | ៣៥ | ៦៤១ | ៣៥៨ |
| ១២ | ខេត្តកោះកុង | ១,៦០៦ | ២៧,៤២០ | ១២,៧០៤ | ៣៦៣ | ៦,២៥៧ | ២,៨៨០ |
| ១៣ | ខេត្តកំពត | ៩៩០ | ៤៩,១៩៩ | ២៦,៧៧២ | | | |
| ១៤ | ខេត្តកំពង់ធំ | ៥៥៨ | ៣៨,៩៦១ | ២០,៦៦៣ | ២៦៧ | ១០,១៩៤ | ៥,៧៦១ |
| ១៥ | ខេត្តតាកែវ | ១៦ | ៥៧០ | ៣០២ | ៩២ | ៣,៤៥១ | ២,១៣៨ |
| ១៦ | ខេត្តក្រចេះ | ៥២ | ៩៧៣ | ៥៧៨ | | | |
| ១៧ | ខេត្តកែប | ៥៦ | ៩,១៤៧ | ៣,៨៨៥ | ១០៤ | ៤,៤៨៤ | ២,៥៨២ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៦៧៩ | ៣០,០៤១ | ១៦,៦០៩ | ១២១ | ៤,២៥០ | ២,៥៩៧ |
| ១៩ | ខេត្តស្ទឹងត្រែង | ៤១០ | ២៥,៦៦៨ | ១៣,៩២២ | ៣៤០ | ១៣,១៥២ | ៧,៤៤៤ |
| ២០ | ខេត្តរតនគិរី | ៦៣៦ | ២៩,២៧៦ | ១៥,២៦១ | ៣៥៩ | ១៧,៥៥៨ | ៨,៨០៥ |
| ២១ | ខេត្តព្រៃវែង | ១,០៣១ | ៥៣,៩០១ | ២៩,៦៩៤ | ៧១៧ | ២១,១៥៣ | ១១,៥៦៩ |
| ២២ | ខេត្តត្បូងឃ្មុំ | ០៣ | ៣៤៩ | ២២៣ | ១៣០ | ៣,៧៨៦ | ១,៦៩៤ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៧៦ | ១៤,៦១១ | ៨,២៥១ | ១៣ | ៩១១ | ៦៦២ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៦៣ | ៤,២៨៨ | ២,០២៣ | ៣០ | ១,១០៩ | ៥២៩ |
| សរុប | | ១៥,០៤៩ | ៨០៨,៨៤១ | ៤៣១,៣៦៥ | ៧,៦៨១ | ២៩១,៧៧៧ | ១៥៧,៦៩៩ |
| សរុបរួម | | ២២,៧២៨ លើក | | ១,១០០,៦១៨ នាក់ | | ៥៨៩,០៦៤ នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | រាជធានី ខេត្ត | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកែប | ០៣ | ១,០៤៤ | ៤៩៥ |
| ២ | ខេត្តកំពង់ចាម | ១១ | ៦,៩១៧ | ៤,៦០៤ |
| ៣ | ខេត្តកណ្តាល | ០១ | ៧៣ | ១៨ |
| ៤ | ខេត្តសៀមរាប | ២៥ | ១,៨៣១ | ១,១០៦ |
| ៥ | ខេត្តកំពង់ឆ្នាំង | ០៧ | ៣៥២ | ១១៤ |
| ៦ | ខេត្តមណ្ឌលគិរី | ០៣ | ២៨៧ | ១៨០ |
| ៧ | ខេត្តកំពង់ស្ពឺ | ០៩ | ១៤៣ | ៤៦ |
| សរុប | | ៥៩ លើក | ១០,៦៤៧ នាក់ | ៦,៥៦៣ នាក់ |

**ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់**

❖ **ការផលិត និងចែកផ្សាយ សម្ភារផ្តល់ព័ត៌មាននិងអប់រំ** IEC ( Information Education Communication Materials)

▪ **រាជធានីភ្នំពេញ៖** រដ្ឋបាលក្រុងបានផ្សព្វផ្សាតាមរយៈ DVD Video ផ្តល់ការអប់រំស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អ្នកទេសចរសរុបចំនួន ៧៤៩,០០០នាក់ ទេសចរជាតិ ៧២៧,០០០នាក់ ទេសចរបរទេស ២២,០០០នាក់ (តាមផ្លូវថ្មើជើងចតុមុខ)។

▪ **ខេត្តសៀមរាប៖**

- ក្រុមការងារក្រុងសៀមរាប និងស្រុកពួក ចែកខិត្តប័ណ្ណផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ការធ្វើចំណាកស្រុក ការស្វែងរកជំនួយ និងលេខទូរស័ព្ទអាជ្ញាធរមានសមត្ថកិច្ច ជូនប្រជាពលរដ្ឋ បានចំនួន ១២,៤៤៤សន្លឹក

- មជ្ឈមណ្ឌលការងារខេត្ត ផ្សព្វផ្សាយនិងចែកខិត្តប័ណ្ណ/កម្មវិធី អំពីព័ត៌មានទីផ្សារការងារ បានចំនួន ២,០០០ខិត្តប័ណ្ណ/កម្មវិធី

- អង្គការមូលនិធិអេ២១ ចែកសាប៊ូមានភ្ជាប់ប័ណ្ណរាយការណ៍ ករណីសង្ស័យថាជាអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋភៀសសឹក ក្នុងស្រុកអង្គរធំ និងស្រុកប្រាសាទបាគង ចំនួន ៨៣៥ខិត្តប័ណ្ណ។

▪ **ខេត្តឧត្តរមានជ័យ៖** បានចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងចែកខិតប័ណ្ណ ចំនួន ១,០០៧សន្លឹក នៅតាមគោលដៅទេសចរណ៍ចំនួន ៤៣កន្លែង រួមមាន៖ រមណីយដ្ឋានប្រវត្តិសាស្ត្រអន្លង់វែង តំបន់វប្បធម៌ប្រវត្តិសាស្ត្រប្រាសាទបុរាណ តំបន់ធម្មជាតិ កសិ-ទេសចរណ៍ តំបន់គោលដៅទេសចរណ៍ និងសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ មានចំនួន ៧កន្លែង។

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

▪ **រាជធានីភ្នំពេញ៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំខ្លីៗ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ បានចំនួន ១២០លើក។

▪ **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានផលិតកម្មវិធី២សំខាន់ៗ ធ្វើការផ្សាយផ្ទាល់តាមរយៈវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត ទូរទស្សន៍ខ្សែកាបអង្គរ តាមប្រព័ន្ធអនឡាញ ស្តីពីការទប់ស្កាត់អំពើហិង្សានៅក្នុងគ្រួសារ ការធ្វើចំណាកស្រុកខុសច្បាប់ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បានចំនួន ១៦៤លើក ក្នុងនោះផ្សាយផ្ទាល់ ៣៩លើក ចាក់ផ្សាយឡើងវិញ ១២៥លើក។

▪ **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុ ស្តីពីដំណើរការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ការបង្ការទប់ស្កាត់ពលកម្មកុមារខុសច្បាប់ និងការធ្វើចំណាកស្រុកដោយស្របច្បាប់ ចំនួន ៥លើក។

▪ **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយសារអប់រំនៃការជួញដូរមនុស្ស តាមវិទ្យុបារាយណ៍អណ្តែត បានចំនួន ៥០ដង ដោយក្នុង១ថ្ងៃ ៥លើក។

▪ **ខេត្តកោះកុង៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១៨០លើក។

▪ **ខេត្តតាកែវ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ២៥ដង។

▪ **ខេត្តត្បូងឃ្មុំ៖** មន្ទីរព័ត៌មាន បានចាក់ស្ប៉ុតអប់រំតាមរយៈវិទ្យុជាតិ ស្តីពីការជួញដូរក្រៅប្រទេស បានចំនួន ១២៥ដង និងខ្លឹមសាររឿងពាក់ព័ន្ធការជួញដូរផ្លូវភេទចំនួន ៣២ដង។

▪ **ខេត្តប៉ៃលិន៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងមួយថ្ងៃ៨លើក ស្មើនឹង ៤៩៦លើក ក្នុងមួយខែ។

▪ **ខេត្តកំពង់ស្ពឺ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុជាតិគិរីរម្យ អំពីស្ប៉ុតការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ រៀងរាល់ថ្ងៃក្នុងមួយថ្ងៃផ្សាយ ២០លើក សរុបចំនួន ៦០០លើក។

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ និងនៅតាមស្ថានីយវិទ្យុ ទូរទស្សន៍**

▪ **អគ្គលេខាធិការដ្ឋាន គ,ជ,ប,ជ** លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ, ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ បានអញ្ជើញផ្តល់កិច្ចសម្ភាសន៍ផ្ទាល់ជាមួយ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ស្តីពីការបង្កើតលក្ខខ័ណ្ឌការងារដែលមានសុវត្ថិភាពជាងមុន មានគណនេយ្យភាពជាងមុន និងមានការចូលរួមកាន់តែទូលំទូលាយសម្រាប់ស្ត្រី ជនចំណាកស្រុក និងកម្មករនៅក្នុងវិស័យដែលមានភាពងាយរងគ្រោះនៅកម្ពុជា នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ ខេត្តសៀមរាបៈ ស្នងការរងទទួលផែនការងារអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្ត បាន អញ្ជើញចូលរួមជាវាគ្មិនក្នុងស្ថានីយវិទ្យុ ១លើក ស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ។

**ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

❖ ការផ្សព្វផ្សាយ

▪ ខេត្តតាកែវៈ បានប្រជុំផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ នៅតាមក្រុមហ៊ុនចំនួន ០៣លើក/០៣ក្រុមហ៊ុន រួមមានក្រុមហ៊ុន សាយ ហ្វេសិន (ខេមបូឌា)ឯ.ក, ក្រុមហ៊ុន យូនី ហ្វាន (ខេមបូឌា)ឯ.ក និងក្រុមហ៊ុន ដេននីស អេឡិកទ្រី ឯ.ក មានអ្នកចូលរួម ២៨នាក់ ស្រី ១២នាក់។

❖ ការធ្វើអធិការកិច្ចការងារ

▪ ខេត្តកណ្តាលៈ មន្ទីរការងារ បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះធ្វើអធិការកិច្ចការងារពិសេសចំនួន ៥លើក ស្មើនឹង ៥សហគ្រាស គ្រឹះស្ថាន ចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស និងលក្ខខណ្ឌការងារ។ ក្នុងនោះមានសហគ្រាស គ្រឹះស្ថាន ៣ ត្រូវបានក្រុមកាងារធ្វើការដាក់កំហិត និងសហគ្រាស គ្រឹះស្ថាន ២ ត្រូវបានក្រុមកាងាររៀបចំឯកសារត្រៀមផាកពិន័យ។

▪ ខេត្តសៀមរាបៈ មន្ទីរការងារងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងកម្មករខ្មែរ និងបរទេស និងការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ

- ធ្វើបច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីបញ្ចូលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសរុបចំនួន ៣,៣៧២សហគ្រាស មានកម្មករនិយោជិត ចំនួន ៣៨,៥១៦នាក់ ស្រី ១៨,០៩០នាក់
- បានផ្តល់សៀវភៅការងារទិដ្ឋាការចេញ-ចូល លើសៀវភៅការងារដល់កម្មករ និយោជិតខ្មែរ សរុប ១៨៦នាក់ ស្រី ៥៥នាក់
- បានបានផ្តល់ប័ណ្ណការងារជនបរទេស ចំនួន ៣៣៣នាក់ ស្រី ១៣២នាក់ (ផ្តល់ប័ណ្ណការងារថ្មី និងទិដ្ឋាការចូល ៦នាក់ ស្រី ៤នាក់ និងពន្យាសុពលភាពលើប័ណ្ណការងារ ៣២៧នាក់ ស្រី ១២៨នាក់)
- បានពិនិត្យ លើការស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស ចំនួន ១៩ក្រុមហ៊ុន។

**ក.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរតាមផ្លូវច្បាប់ បានចំនួន ១៨៥នាក់ ស្រី ៦នាក់ មាន១៤សញ្ជាតិ រួមមាន ចិន៩៨, កូរ៉េខាងត្បូង៣៦ ស្រី១, អាម៉េរិក២០ ស្រី២, បារាំង៤, អូស្ត្រាលី៨ ស្រី២, អង់គ្លេស២, ជប៉ុន១, ឥណ្ឌូនេស៊ី១, មីយ៉ាន់ម៉ា៣, នេប៉ាល់១ អាហ្វ្រិកខាងត្បូង១, ម៉ាឡេស៊ី៨ ស្រី១, អៀរឡង់១, ទួគី១។ *និងបានវាយតម្លៃបញ្ជូនឯកសារទៅក្រុមការងារចម្រុះប្រកចេញ-ចូលតែមួយចំនួន ១៥២នាក់ ស្រី ៤នាក់។*

**ក.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស**

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិៈ ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង រាជធានី ខេត្ត ចំនួន ៤២,១៨២នាក់ ស្រី ១៧,៨៩៦នាក់ អនីតិជន ៣៩៦នាក់ ស្រី ១៤៦នាក់ ក្នុងនោះ ៖

- ស្របច្បាប់ចំនួន ៣៥,៧៣៣នាក់ ស្រី ១៥,០០៤នាក់ អនីតិជន ១៦២នាក់ ស្រី ៦០នាក់
- មិនស្របច្បាប់ចំនួន ៦,១៧៦នាក់ ស្រី ២,៧៨៧នាក់ អនីតិជន ២១៤នាក់ ស្រី ៧៩នាក់
- ដាច់ការទាក់ទងចំនួន ២៧៣នាក់ ស្រី ១០៥នាក់ អនីតិជន ២០នាក់ ស្រី ០៧នាក់។

- ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ១៤,៩៨៧នាក់ ស្រី ៦,៨៦៣នាក់ អនីតិជន ៣៣៨នាក់ ស្រី ១៣១នាក់។

▪ **លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖** បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និង បានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករចំណាកស្រុក ទៅក្រៅប្រទេស | | | | ចំនួនពលករវិលត្រឡប់ ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្ដាល | ៦,៣៤៨ | ៣,៣៧១ | ៤០ | ១៨ | ៩២១ | ៤២៤ | ៤១ | ២២ |
| ២ | កំពង់ចាម | ១២,៨២៣ | ៥,៨៨៨ | ០៦ | ០៤ | ៧,៥២០ | ៣,៨២០ | ១៤២ | ៨៨ |
| ៤ | កំពង់ឆ្នាំង | ៣៩ | ១៦ | | | ១២ | ០៣ | | |
| ៥ | កំពង់ស្ពឺ | ៩៣៣ | ១៦៨ | | | ០៨ | ០៣ | | |
| ៦ | កំពត | ៩,៦៨១ | ៤,០១៦ | ៥៥ | ៣៤ | ៦,៣៥០ | ២,៩៣៨ | | |
| ៧ | កែប | ២០៨ | ១០០ | | | | | | |
| ៨ | ក្រចេះ | ១,៨៥១ | ៨៣៣ | | | ២,០៥៨ | ៨៨៩ | ៨៧ | ៣៥ |
| ៩ | តាកែវ | ១,៩៤៧ | ១,០៧៥ | | | | | | |
| ១០ | ត្បូងឃ្មុំ | ១២,៥៨៨ | ៥,៤៦៧ | ៧២ | ៣៩ | | | | |
| ១១ | បាត់ដំបង | ៧០១ | ៣៣០ | | | ៥៣២ | ២៥២ | ៤២ | |
| ១២ | ប៉ៃលិន | ២៦ | ១៣ | ០៥ | ០២ | | | | |
| ១៣ | ពោធិ៍សាត់ | ៥៨៥ | ៣១០ | ១៩ | ០៦ | ០៩ | ០៤ | | |
| ១៤ | ព្រះវិហារ | | | | | ១,១៤២ | ៥០០ | | |
| ១៥ | ព្រះសីហនុ | ២១ | ១២ | | | | | | |
| ១៦ | ព្រៃវែង | ១១៣ | ២៦ | | | ១៤២ | ៥៤ | ០៥ | ០២ |
| ១៧ | មណ្ឌលគិរី | ៨០ | ២៨ | ១៣ | ០៥ | | | | |
| ១៨ | សៀមរាប | ២២,៣៦០ | ១០,៤៧១ | ១,១៨៥ | ៥៧៦ | ៤៣០ | ១៩៨ | ៥៧ | ៣៣ |
| ១៩ | ស្វាយរៀង | ៦,១៨៦ | ២,៤៦៣ | | | ៤,០៥៩ | ១,៦៥៤ | | |
| ២០ | ស្ទឹងត្រែង | ៥៩៤ | ៣១១ | ១១ | ០៧ | | | | |
| ២១ | ឧត្តរមានជ័យ | ៩,១៧៦ | ៤,៦៨៩ | ០២ | | | | | |
| | សរុបរួម | ១៥៦,២៦០ | ៣៩,៥៨៧ | ១,៤០៨ | ៦៩១ | ២៣,១៨៣ | ១០,៧៣៩ | ៣៧៤ | ១៨០ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

- <u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ)</u>

▪ **ខេត្តកោះកុង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាម ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន ២លើក មនុស្សចំនួន ១៩នាក់ ស្រី ៦នាក់។

▪ **ខេត្តបាត់ដំបង៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ បានសហការជាមួយ សមត្ថកិច្ចថៃ បានទទួលប្រជាពលរដ្ឋខ្មែរ គ្មានលិខិតឆ្លងដែនត្រឡប់មកវិញចំនួន ០៧លើក ទទួលពលករបាន ៨៥២នាក់ ស្រី ៣៧៤នាក់ អនីតិជន ២៥នាក់ បានធ្វើការអប់រំ និងបញ្ជូនទៅលំនៅដ្ឋានវិញ។

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មណ្ឌលទទួលពលករកំរៀង បានទទួលពលករខ្មែរបញ្ជូនត្រឡប់ពីអាជ្ញាធរថៃ ចំនួន ២,៧៧៤នាក់ ក្នុងនោះស្ត្រីមាន ១,១៨៦នាក់ (ស្ត្រីមានកូនតូចមកជាមួយ ២៤១នាក់ និងស្ត្រីមានផ្ទៃពោះ ៤៩នាក់) អនីតិជន ១៧៦នាក់ (ដោយក្នុងនោះអនីតិជនជាស្ត្រី ៨៤នាក់) និងជនមានពិការភាព ១៣នាក់ (ស្ត្រី ៤នាក់)។

**ក.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ ការផ្សព្វផ្សាយ

▪ **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយ នាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរ ចុះយុទ្ធនាការផ្សព្វផ្សាយស្តីពី ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងចងបដាផ្សព្វផ្សាយនៅតាម សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យផលិតឥដ្ឋនិងក្បឿង បានចំនួន ៧៥លើក ដែលមានកម្មករនិយោជិតចូលរួមចំនួន ១,៦៦៩នាក់ ស្រី ៨១៦នាក់។

▪ **ខេត្តក្រចេះ៖** មន្ទីរឧស្សាហកម្ម និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ បានចុះផ្សព្វផ្សាយតាមបណ្តាមូលដ្ឋានជញ្ជីងតោន និងសិប្បកម្មបិតស្រា នៅក្នុងខេត្តក្រចេះ បានចំនួន១២មូលដ្ឋាន ស្តីពីការហាមឃាត់ប្រើប្រាស់ពលកម្មកុមារ ការកេងប្រវ័ញ្ច ការទប់ស្កាត់រាល់សកម្មភាពជួញដូរនិងប្រើហិង្សាលើបុគ្គលិកកម្មករ (ពិសេសកុមារ) មានបុគ្គលិកចំនួន ២៤នាក់ ស្រី ៥នាក់ និងអប់រំបុគ្គលិកដែលធ្វើការតាមបណ្តារោងចក្រសិប្បកម្ម ដែលមានកូន ឱ្យបញ្ជូនកូនឱ្យចូលសិក្សាគ្រប់គ្នា។

❖ អធិការកិច្ច

▪ **ខេត្តកណ្តាល៖**-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអាជ្ញាធរ ចុះធ្វើកិច្ចសន្យាជាមួយអាណាព្យាបាលចំនួន ៦៩៤គ្រួសារ ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ជាមួយម្ចាស់សហគ្រាស គ្រឹះស្ថាន ចំនួន ៧៥សហគ្រាស គ្រឹះស្ថាន។

▪ **ខេត្តប៉ៃលិន៖** បានផ្សព្វផ្សាយ និងធ្វើកិច្ចសន្យាជាមួយម្ចាស់សហគ្រាសទាំង៥ ដើម្បីចូលរួមលុបបំបាត់ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ និងការពារសុវត្ថិភាពកុមារក្នុងខ្សែច្រវ៉ាក់ផលិតកម្ម។

**ក.៥. ការលើកកម្ពស់ជីវភាព**

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ខេត្តសៀមរាប៖

- **មជ្ឈមណ្ឌលការងារខេត្ត** បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន ១៥០កន្លែង។ បានរៀបចំពិព័រណ៍ការងារចល័ត និងវេទិកាការងារ បានចំនួន ៥លើក ដែលមានអ្នកចូលរួមសរុប ៤,៨៧១នាក់ ស្រី ២,៧៦៣នាក់។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ១,០៣៥នាក់ ស្រី ៥១៩នាក់ (ពលករ ៩១៤នាក់ ស្រី ៤៧៧នាក់) ។ បានផ្គូរផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ២៤២នាក់ ស្រី ៥៦៣នាក់ (ពលករ ២,២៩៥នាក់ ស្រី ៥២៧នាក់)។ អ្នកទទួលបានការងារធ្វើសរុប ៨៦២នាក់ ស្រី ៣៥៩នាក់ (ពលករ ៨២៤នាក់ ស្រី៣៤៣នាក់)។ ផ្តល់ការប្រឹក្សាអំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើ បានចំនួន ៥៦៤នាក់ ស្រី ២៤៥នាក់។ បានចែកខិតប័ណ្ណអំពីព័ត៌មានទីផ្សារការងារ បានចំនួន ២,០០០ ខិតប័ណ្ណ/កម្មវិធី។

- **វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ** បានចុះផ្សព្វផ្សាយ និងប្រឹក្សាយោបល់ដល់យុវជន អំពីនីតិវិធីចុះឈ្មោះសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងកិច្ចប្រជុំ កម្មវិធីពិព័រណ៍ការងារ ពិព័រណ៍មគ្គុទ្ទេសក៏អាជីព និងការសិក្សា បានចំនួន ៨លើក។

- វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប បានចុះផ្សព្វផ្សាយនៅក្នុងកម្មវិធី ជំរុំយុវវ័យ វេទិកាការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិព័រណ៍មគ្គុទេសក៍អាជីព និងការសិក្សា ពិព័រណ៍ការងារ និងកម្មវិធីវិថីឆ្ពោះទៅកាន់ការអភិវឌ្ឍការងារ និងវិជ្ជាជីវៈ ដែលរៀបចំដោយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការការីតាស់ស្វីស អង្គការសហព័ន្ធជាតិសមាគមយុវណោស្កូជប៉ុនប្រចាំកម្ពុជា និងអង្គការសម្រេចសុបិន្តកុមារកម្ពុជា នៅស្រុកស្រីស្នំ ស្រុកក្រឡាញ់ ក្រុងរុនតាឯក ស្រុកបន្ទាយស្រី និងខេត្តបន្ទាយមានជ័យ សរុប ១០លើក មានអ្នកចូលរួមសរុប ៦,៨០៨នាក់ ស្រី ៣,៩០៨នាក់។

- អង្គការ Friend International បានស្វែងរកការងារ និងគាំទ្រអតិថិជនឱ្យមានការងារ និងមុខរបរ សរុប ចំនួន ៥៦នាក់ ស្រី ៣៩នាក់ ដោយក្នុងនោះ មានអតិថិជនបានដាក់ឱ្យមានការងារធ្វើសរុបចំនួន ៣១នាក់ ស្រី ២១នាក់ និងអតិថិជនសរុបចំនួន ២៥នាក់ ស្រី ១៨នាក់ បានដាក់ជាមុខរបរអាជីវកម្មខ្នាតតូច។

▪ **រាជធានីភ្នំពេញ៖** បានផ្តល់ព័ត៌មានស្តីពីតម្រូវការកម្លាំងពលកម្មក្នុងរាជធានីភ្នំពេញ ទៅទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) តាមរយៈ Group Telegram របស់មន្ទីរ ដែលមានសហគ្រាស គ្រឹះស្ថាន ចំនួន ៣០ ទីតាំង កំពុងមានតម្រូវការកម្លាំងពលកម្ម ចំនួន ២២៩នាក់ ស្រី ១០២នាក់។ ក្រុមការងារក៏បានចុះផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅតាមខ្នងផ្ទះបានចំនួន ១៥១ខ្នងផ្ទះ មានប្រជាពលរដ្ឋចូលរួម ៤៧៥នាក់ នៅភូមិត្រពាំងល្វា២ ភូមិក្បាលដំរី១ ភូមិតាងួន១ តាងួន២ ភូមិប៉ប្រកខាងត្បូង និងភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

▪ **ខេត្តព្រៃវែង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ បានចំនួន ១៨,៤០៩នាក់ ស្រី ៧,៩៧៧នាក់ ក្នុងចំណោមពលករចំនួន ២២,១៦៨នាក់ ស្រី ៩,៥៦៩នាក់។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាមួយបុគ្គលិកមណ្ឌលទទួលពលករកំរៀងផ្សព្វផ្សាយស្តីពី "ការរកការងារធ្វើក្នុងស្រុក ការរៀនជំនាញវិជ្ជាជីវៈ ការប្រកបមុខរបរខ្នាតតូច ការធ្វើកសិកម្ម និងបញ្ហាបសុវត្ថិភាពទេសន្តរប្រវេសន៍ ការការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងញៀននៅមូលដ្ឋាន នៅស្រុកភ្នំព្រឹក (២លើក) អ្នកចូលរួម ៦៥នាក់ ស្រី ៣៩នាក់។ បានជួយរកការងារ ផ្តល់ព័ត៌មានការងារ ចុះឈ្មោះរកការងារក្នុងប្រព័ន្ធ១,២៩៧ និងទំនាក់ទំនងសហគ្រាសរកតម្រូវការកម្លាំងពលកម្ម ដើម្បីឱ្យពលករ ពលការនីចូលបម្រើការងារ។

▪ **ខេត្តប៉ៃលិន៖**

- បានផ្សព្វផ្សាយអំពីវគ្គសិក្សាបច្ចេកទេសវិជ្ជាជីវៈ ក្នុងវេទិកាការការងារក្នុងស្រុកសាលាក្រៅ និងក្រុងប៉ៃលិន ដែលមានប្រជាពលរដ្ឋ សិស្សានុសិស្ស និងពលករបានចុះឈ្មោះចូលរៀន ចំនួន៣៨នាក់ ស្រី០៩នាក់។

- បានចុះស្រង់ស្ថិតិតម្រូវការជ្រើសរើសកម្មករនិយោជិតតាមសហគ្រាសគ្រឹះស្ថានក្នុងខេត្ត(បច្ចុប្បន្នមាន ១៨ សហគ្រាស គ្រឹះស្ថាន កំពុងត្រូវការជ្រើសរើសកម្មករនិយោជិតចំនួន ១២៩នាក់ ស្រី ៨៥នាក់)។

- បានផ្សព្វផ្សាយព័ត៌មានទីផ្សារការងារដល់ប្រជាពលរដ្ឋជាពិសេសពលករ ចំនួន ១លើក ដោយការចងបដាព័ត៌មាននៅតាមទីសាធារណៈ និងការផ្សព្វផ្សាយក្នុងហ្វេសប៊ុកផេកផ្លូវការ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

▪ **ខេត្តព្រះវិហារ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេក និងគ្រុបតេលេក្រាមមន្ទីរការងារ ជាមួយសហគ្រាស គ្រឹះស្ថានក្នុងខេត្ត និងចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន ១៦សន្លឹក អ្នកទទួលបាន ៤៦២នាក់ ស្រី ១៣១នាក់។

▪ **ខេត្តរតនគិរី៖** ពលករវិលត្រឡប់ពីប្រទេសថៃនៅក្នុងខេត្ត និងមកពីខេត្តផ្សេង បានចូលធ្វើការតាមរយៈក្រុមហ៊ុន ឬតាមក្រុមគ្រួសារ ចំនួន ៤៣៥នាក់ ស្រី ១៦៣នាក់ និងបានចូលធ្វើការតាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬលេខទូរស័ព្ទ ១២៩៧ ចំនួន ១១៩នាក់ ស្រី ៥៥នាក់។

❖ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត

▪ **ខេត្តកំពង់ចាម៖** មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្ត បានបើកវគ្គបណ្តុះបណ្តាល (កាត់ដេរ ត្បាញ សម្អាងកាយ) ដើម្បីបង្កើនជាមុខរបរចិញ្ចឹមជីវិត ចូលរួមកាត់បន្ថយភាពក្រីក្រនៅសហគមន៍ បាន ៣វគ្គ អ្នកចូលរួម ចំនួន ១១០នាក់(ស្រី)។

▪ **ខេត្តកំពង់ឆ្នាំង៖** មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី នៃមន្ទីរកិច្ចការនារី បានទទួលសិស្សចុះឈ្មោះចូលសិក្សា វគ្គថ្មីឆ្នាំ២០២៦ លើមុខជំនាញ វិជ្ជាជីវៈនូវជំនាញកាត់ដេរ សម្អាងកាយ និងតម្បាញ វគ្គ១ ចំនួន ៩៥នាក់(ស្រី)។

▪ **ខេត្តសៀមរាប៖** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការបណ្តុះបណ្តាលដល់កសិករនៅ ឃុំត្រីញ៉រ ស្រុកពួក អំពីបច្ចេកទេសប្រព័ន្ធកសិកម្មចម្រុះ ចំនួន ០១លើក មានកសិករចូលរួម ៤០នាក់ ស្រី ៣៤នាក់។

▪ **ខេត្តមណ្ឌលគិរី៖** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបណ្តុះបណ្តាលកម្រិត បច្ចេកទេស និងវិជ្ជាជីវៈ កុំព្យូទ័រ និងសម្អាងកាយ ចំនួន ០២វគ្គ ចំនួន១២៥នាក់ ស្រី១១៧នាក់។

▪ **ខេត្តស្វាយរៀង៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយ នូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជា អ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារសុខភាព និងសុវត្ថិភាពការងារ និងការជួយ សង្គ្រោះបឋមចំនួន ២វគ្គ អ្នកចូលរួមចំនួន ១០២នាក់ ស្រី៦០នាក់។

▪ **ខេត្តប៉ៃលិន៖** បានបើកវគ្គបណ្តុះបណ្តាល (កាត់ដេរ អ៊ុតសក់ សម្អាងកាយ) ដល់ស្ត្រីមេម៉ាយ ក្មេង ស្រីបោះបង់ការសិក្សា ស្ត្រីជាប់ពន្ធនាគារ ដើម្បីបង្កើនជាមុខរបរចិញ្ចឹមជីវិត ចូលរួមកាត់បន្ថយភាពក្រីក្រនៅសហគមន៍ បាន ១វគ្គ អ្នកចូលរួម ចំនួន ៦៤នាក់ (ស្ត្រីជាប់ពន្ធនាគារ ២៤នាក់)។

### ក.៦. ការសិក្សាស្រាវជ្រាវ

▪ **ខេត្តកណ្តាល៖** ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះសិក្សាស្រាវជ្រាវអំពីទិន្នន័យកុមារ ដែល ឪពុកម្តាយធ្វើចំណាកស្រុក ដើម្បីទៅរកការងារធ្វើនៅក្នុង និងក្រៅប្រទេស ដែលត្រូវរស់នៅជាមួយជីដូនចាស់ជរា។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

ក្រុមការងារការអនុវត្តច្បាប់ នៃ គ,ជ,ប,ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយក ដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ១៧/១៤ករណី (កើន ៣ករណី) ស្មើនឹង២១,៤២%

- ឃាត់ខ្លួនជនសង្ស័យ ចំនួន ២០នាក់ ស្រី ២នាក់ ។
- សង្គ្រោះជនរងគ្រោះចំនួន ៤៨នាក់ ស្រី ៣១នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ១១នាក់(ស្រី៩នាក់) អាយុ១៥-១៧ឆ្នាំ ៣នាក់ ស្រី២នាក់ អាយុ១៨ឆ្នាំឡើង ៣៤នាក់ ស្រី២០នាក់ និងបានបញ្ជូនទៅមន្ទីរ សង្គមកិច្ច ៣នាក់ និងទៅគ្រួសារ ៤៥នាក់។

  ក្នុងនោះចែកជា៖

+ <u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ០៩/០៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ ស្រី១នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ៣៨នាក់ ស្រី២១នាក់ មានអាយុ១៥-១៧ឆ្នាំ ៤នាក់ ស្រី២នាក់ អាយុ១៥-១៧ឆ្នាំ ២នាក់ ស្រី ១នាក់ និង អាយុ១៨ឆ្នាំឡើង ៣២នាក់ ស្រី១៨នាក់ បានបញ្ជូនទៅគ្រួសារទាំងអស់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៨ | ១០ | ៣៧(២០) |
| អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០១(០១) |
| *សរុប* | *០៩ករណី* | *១១នាក់* | *៣៨(២១)នាក់* |

- **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ០៨/១១ករណី (ថយចុះ ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៩នាក់ ស្រី០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១០នាក់(ស្រី) មានអាយុក្រោម១៥ឆ្នាំ ០៧នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ០៣នាក់ គ្រួសារ ០៧នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០២ | ០៣(០៣) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | ០១(០១) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | ០៥(០៥) |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១(០១) |
| *សរុប* | *០៨ករណី* | *០៩នាក់* | *១០(១០)នាក់* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ,ជ,ប,ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងក្រៅប្រទេសចំនួន ២២នាក់(ប្រុស១នាក់ ស្រី ១៨នាក់ កុមារី៣នាក់) ក្នុងនោះ៖

- ក្នុងប្រទេស ជាជនបរទេស ២នាក់(កុមារី) មានជនជាតិចិន ១នាក់(សញ្ញារកម្ម) និងអាល្លឺម៉ង់ ១នាក់(ងាយរងគ្រោះ)។
- មកពីប្រទេសចិនចំនួន ២០នាក់ (ប្រុស១នាក់ ស្រី១៨នាក់ កុមារី១នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ១៩នាក់ និងងាយរងគ្រោះ ១នាក់។

➢ *បានធ្វើការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញសរុបចំនួន ២២នាក់ (ប្រុស ១នាក់ ស្រី១៨នាក់ កុមារី៣នាក់)។*

### គ.២. ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូចំនួន ២២នាក់(ប្រុស១នាក់ ស្រី១៨នាក់ កុមារី៣នាក់) ក្នុងនោះ៖ អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ៦នាក់ស្រី អង្គការការីតាសកម្ពុជា ៦នាក់(ប្រុស១នាក់ ស្រី៣នាក់ កុមារី២នាក់) អង្គការមូលនិធិហាការអន្តរជាតិ ៣នាក់ និងអង្គការសម្ព័ន្ធចាប់ដៃ ៧នាក់។

**គ.៣. ការធ្វើមាតុភូមិនិវត្តន៍**

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសដើមវិញ ចំនួន ៣នាក់(ស្រីជនជាតិឡាវ)។

**គ.៤. ការធ្វើសមាហរណកម្ម**

បានសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍ ចំនួន១៣នាក់(ស្រី១១នាក់ កុមារី២នាក់)។

**គ.៥. ការតាមដានជនរងគ្រោះ**

បានតាមដានជនរងគ្រោះ ចំនួន ២០៦នាក់(ប្រុស៥នាក់ ស្រី៦៨នាក់ កុមារា១៧នាក់ កុមារី១១៦នាក់)។

**គ.៦. ការបិទករណីជនរងគ្រោះ**

បានបិទករណី ជនរងគ្រោះ ចំនួន ៣នាក់(ស្រី២នាក់ កុមារី១នាក់)។

## ឃ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

### ឃ.១. លិខិតបទដ្ឋានគតិយុត្ត

▪ អគ្គលេខាធិការដ្ឋាន គ,ជ,ប,ជ៖ បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅក្របខណ្ឌ តាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ,ជ,ប,ជ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៦។

▪ ខេត្តព្រៃវែង៖ បានប្រជុំផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំនិងប្រកាសសមាសភាពគណៈកម្មាការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (online Scams)។

▪ ខេត្តក្រចេះ៖ បានរៀបចំកែសម្រួល និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ,ខ,ប,ជ)។

▪ ខេត្តតាកែវ៖ បានរៀបចំសំណើសុំកែសម្រួលសមាសភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ,ខ,ប,ជ) ទៅក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ៧៦៩/២៥លស ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥។

▪ ខេត្តមណ្ឌលគិរី៖ បានចេញសេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាព លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ,ខ,ប,ជ)។

# III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្រ្តី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការមេត្រីអន្តរជាតិ (AIM SWAT) បើកវគ្គបណ្តុះបណ្តាលស្តីពី យុទ្ធវិធីប្រតិបត្តិការ ដល់មន្ត្រីជំនាញនាយកដ្ឋាន។ | ០១ | ២០ | ០១ |
| | ខេត្តសៀមរាប៖ ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកពួក បានសហកាជាមួយអង្គការទស្សនពិភពលោក រៀបចំវគ្គបណ្តុះបណ្តាលស្តីពី យន្តការនៃការរាយការណ៍ និងការបញ្ជូន នៅសហគមន៍ឃុំមុខប៉ែន។ | ០១ | ៣៣ | ២៩ |
| ២ | ខេត្តស្ទឹងត្រែង៖ ស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស | ០១ | ៣០ | ១១ |
| | *សរុប* | *០៣វគ្គ* | *៨៣នាក់* | *៤១នាក់* |

### ក.២. សិក្ខាសាលា

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីសម្បទា

- សហការជាមួយអង្គការ WORLD HOPE International រៀបចំសិក្ខាសាលាបើកវគ្គបណ្តុះបណ្តាល អំពី «ផ្ទះមានសុវត្ថិភាព សុខមាលភាពដល់គ្រួសារ ប្រឆាំងទៅនិងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ» ក្រោម អធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួង ស,អ,យ, នៅសណ្ឋាគារសាន់អេនមូន មានអ្នកចូលរួម ៤៦នាក់ ស្រី២៩នាក់។

- សហការជាមួយគម្រោង JICA បានរៀបចំសិក្ខាសាលាតាមដានលើការប្រើប្រាស់ទម្រង់របាយការណ៍ ស្តីពី «ការផ្តល់សេវាគាំពារជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ» ក្រោមអធិបតីភាព ឯកឧត្តម អ៊ុំ សុផាន់ណារ៉ា អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច នៅសណ្ឋាគារកាំបូឌីយ៉ាណា មានអ្នកចូលរួម ៤៥នាក់ ស្រី២៥នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន ៧លើក មានអ្នកចូលរួមចំនួន ៤៩នាក់ ស្រី ១០នាក់ ក្នុងនោះ៖

- កិច្ចជុំចង្អៀត ដើម្បីពិនិត្យជាតុចូល សម្រាប់ការឆ្លើយតបទៅនឹងការត្រៀមរៀបចំរបាយការណ៍វាយ តម្លៃរបស់ក្រសួងការបរទេសអាម៉េរិក ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការ ប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស។ ដោយមានសមាសភាព ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋាន កណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគបាលជាតិ ក្រសួងមហាផ្ទៃ សរុបចំនួន ៣១រូប ស្រី ៧រូប នៅទីស្តីការ ក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំរៀបចំការងារ ផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់កម្មវិធី ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ សមាសភាពចូលរួមពី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ នៃលិខិតបង្គាប់ការលេខ ១៩២/២៥ ល.ប.ក តំណាងនាយកដ្ឋានអង្គរក្ស នៃអគ្គស្នងការដ្ឋាននគរបាល ជាតិ តំណាងនាយកដ្ឋានសុខាភិបាល នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ សរុបចំនួន ៩នាក់ ស្រី ១នាក់ នៅ បន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ,ជ,ប,ជ។

- កិច្ចប្រជុំពិភាក្សាក្រុមការងារបច្ចេកទេស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយក្រុមការងារ បច្ចេកទេសរបស់អង្គការ យូនីសេហ្វ UNICEF ស្តីពីការបន្តផែនការសកម្មភាពឆ្នាំ២០២៦ នៃការប្រមូលទិន្នន័យ កុមាររងគ្រោះ ដោយការធ្វើចំណាកស្រុក ក្នុងគ្រួសារទេសន្តប្រវេសន៍ ដែលមានការចូលរួមពី តំណាងអង្គការ យូនី សេហ្វ និងក្រុមការងារបច្ចេកទេសរបស់ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ចំនួន ៤លើក៖

○ កិច្ចប្រជុំ ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពិនិត្យរបាយការណ៍ការ ឆ្លើយតបទៅកាន់ ក្រសួងការបរទេសសហរដ្ឋអាម៉េរិក សម្រាប់ការវាយតម្លៃប្រចាំឆ្នាំ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់ រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

○ កិច្ចប្រជុំចង្អៀត ដើម្បីពិនិត្យការងារត្រៀមរៀបចំកម្មវិធី ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន ២លើក អ្នកចូលរួម ៩នាក់ ស្រី ២នាក់

○ កិច្ចពិភាក្សាត្រៀមរៀបចំកម្មវិធីចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយក សម្ភារៈ គ្រឿងឧបភោគបរិភោគ ផ្ដល់ជូន លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ក្នុងស្រុកសំពៅលូន និងភ្នំព្រឹក ខេត្តបាត់ដំបង។

▪ **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ជាមួយក្រុមការងារជំនាញទាំង៦ ចំនួន ១លើក។

▪ **ខេត្តកណ្ដាល៖**

- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តការងារប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅបន្ត អ្នកចូលរួមចំនួន ៦១នាក់ ស្រី ៥០នាក់។

- ប្រជុំកែសម្រួលរបាយការណ៍ រៀបចំដោយក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត អ្នកចូលរួមចំនួន ៦៣នាក់ ស្រី ៥១នាក់។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ,ខ,ប,ជ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីតាមដាន ពិនិត្យ ពិភាក្សារកដំណោះស្រាយលើភាពប្រឈមនានាពាក់ព័ន្ធនឹងបញ្ហាអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ សរុបចំនួន ១៧លើក មានអ្នកចូលរួមសរុប ៦៥៩នាក់ ស្រី ២៨០នាក់។

▪ **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំស្ដីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ ក្រោមអធិបតីភាពលោកជំទាវ យក់ ស៊ីណាត អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស វត្តមានចូលរួមចំនួន ៥៧នាក់ ស្រី ២៣នាក់។

▪ **ខេត្តព្រះវិហារ៖** លេខាធិការដ្ឋាន គ,ខ,ប,ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមករា ឆ្នាំ២០២៦ ចំនួន ១លើក អ្នកចូលរួមចំនួន ១៥នាក់ ស្រី ៧នាក់។

### ខ.២. ជំនួបពិភាក្សាការងារ

▪ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ,ជ,ប,ជ បានដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋាន ក្នុងជំនួបពិភាក្សាការងារ ជាមួយ នាយកអង្គការ IJM ប្រចាំតំបន់ពិភាក្សាការងារដើម្បីបន្តពង្រឹងកិច្ចសហការ ក្នុងភាពជាដៃគូអភិវឌ្ឍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រជាតិ។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ,ខ,ប,ជ បានជួបពិភាក្សាការងារជាមួយអង្គការមេត្រីអន្តរជាតិ (AIM) ស្ដីពីតម្រូវការរបស់ជនភៀសសឹក និងការរៀបចំផែនការចុះ អប់រំផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការពារកុមារពីការរំលោភបំពាន នៅតាមមណ្ឌលភៀសសឹក ក្នុងមូលដ្ឋានខេត្តសៀមរាប ចំនួន ១លើក។ ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្រុកអង្គរធំ បានទទួលជួបពិភាក្សាជាមួយអង្គការអាស៊ីអេស (ICS) ស្ដីពីការអនុវត្តគម្រោងរួមគ្នាលើកម្មវិធីចិញ្ចឹមកូនតាមបែបវិជ្ជមាន (កម្រិត២) ចំនួន ១លើក។

## គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ៤២លើក។ (**ឧបសម្ព័ន្ធ**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យធកល្វែង
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថាជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ,,, ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាពមិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

### គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស

និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្ដាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះ ដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្ដុះបណ្ដាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋាន ខេត្ត ក្រុង ស្រុក ខណ្ឌ (គ,ខ/រ,ប,ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែមីនា ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៣. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៤. បន្តរៀបចំសកម្មភាពបណ្ដុះបណ្ដាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្ដាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៥. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ៥៥

៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់

៧. បន្តដោះស្រាយឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនរងគ្រោះ

៨. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

៩. រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព៕

ថ្ងៃ.......ខែ.......ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គជបជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គជបជ

-អគ្គលេខាធិការដ្ឋាន គជបជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ការងារសម្របសម្រួល

- លោកជំទាវ ជួ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ
  - កម្មវិធីសន្និបាតពិនិត្យលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំង អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំប្រចាំសប្តាហ៍ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)
  - កម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២៦ ក្រោមប្រធានបទ «ការប្រើប្រាស់បញ្ញាសិប្បនិម្មិត(AI)ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម(ចំការដូង)
  - ជាគណៈអធិបតី សន្និបាតបូកសរុបការងារឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ២០២៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - ជាអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប
  - ជាគណៈអធិបតី ក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋាន ខេត្តកំពង់ឆ្នាំង នៅមន្ទីរបក្សខេត្ត
  - កិច្ចប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា» និងសេចក្តីព្រាងច្បាប់ ស្តីពី «ការបង្ក្រាបអំពើជួញដូរមនុស្ស» ដឹកនាំដោយ ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅទីស្តីការក្រសួងយុត្តិធម៌
  - ជាអធិបតីភាព ក្នុងកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ចំនួន **១២លើក**
  - ជាអធិបតីភាព ក្នុងពិធីបិទសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ខ.ប.ជ រវាងខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ នៅខេត្តសៀមរាប
  - ជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលប្រជុំសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
  - ដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយក្រុមការងារអង្គការ មេត្រីអន្តរជាតិ (AIM) ចុះសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈប្រើប្រាស់ គ្រឿងឧបភោគបរិភោគ ជាកញ្ចប់ជំនួយសង្គ្រោះបន្ទាន់របស់អង្គការ មេត្រីអន្តរជាតិ (AIM) ចែកជូនជនភៀសសឹក សរុបចំនួន ២១០គ្រួសារ ចំនួន២ទីតាំង គឺនៅភូមិតាអុងលិច ឃុំស្វាយចេក ចំនួន ១៤៥គ្រួសារ និងភូមិព្រៃចកី ឃុំតាផូ ចំនួន ៦៥គ្រួសារ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ឆ្លៀតក្នុងឱកាសនោះ នាងខ្ញុំ ក៏បានរួមដំណើរជាមួយគណៈប្រតិភូ ចុះពិនិត្យទីតាំងសាងសង់លំហែនបណ្តោះអាសន្ន សម្រាប់ជនភៀសសឹក មួយកន្លែង ស្ថិតនៅភូមិចក់ពួក ឃុំស្លក្រាម ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
  - ចុះសួរសុខទុក្ខ កងទ័ពដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប ដែលបានរងរបួស ក្នុងអំឡុងសង្គ្រាមឈ្លានពានរបស់ចោរសៀម
  - ចុះពិនិត្យការងារ ត្រៀមសម្រាប់កម្មវិធីយុទ្ធនាការគាំទ្រ ទិវាសុវត្ថិភាពអ៊ីនធឺណេត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» នៅសាលប្រជុំ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ចំការដូង)
  - ចុះពិនិត្យវឌ្ឍនភាពនៃការផលិតវីដេអូបទយកការណ៍ សម្រាប់ចាក់បញ្ចាំងនៅក្នុងកម្មវិធី ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដែលត្រូវធ្វើការកែសម្រួល។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កម្មវិធីបើក និងវិធីកម្មបិទសន្និបាតពិនិត្យលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងបូកសរុបចលនាប្រឡងប្រណាំង អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កម្មវិធីពិធីបិទ សន្និបាតបូកសរុបការងារឆ្នាំ២០២៥ និងលើកទិសដៅឆ្នាំ២០២៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាល បច្ចេកទេស
  - កិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងសេចក្តីព្រាងច្បាប់ស្តីពី ការបង្ក្រាបអំពើរត់ពន្ធមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៅទីស្តីការក្រសួងយុត្តិធម៌
  - ជាគណៈអធិបតី និងធ្វើបទង្ហាញ អំពីសមិទ្ធផលសំខាន់ៗក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ ក្នុងសិក្ខាសាលា ពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូ ឆ្នាំ២០២៦ ដែលសហការរៀបចំដោយក្រសួងយុត្តិធម៌ និង ASEAN-ACT ក្រោមអធិបតីភាព ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ នៅសណ្ឋាគារ SUN&MOON រាជធានីភ្នំពេញ
  - ជាគណៈអធិបតីភាព ក្នុងកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ចំនួន ១២លើក
  - ជាគណៈអធិបតី ក្នុងកម្មវិធីបើកសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ខ.ប.ជ រវាងខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ សិក្ខាសាលានេះប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ សមាសភាពចូលរួមចំនួន ២៨រូប ស្រី ២២រូប នៅសណ្ឋាគារ សោមាទេវី អង្គរ ខេត្តសៀមរាប
  - ជាគណៈអធិបតី ក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសមាសភាពចូលរួមមកពី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន ៥៦រូប ស្រី ១៧រូប នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ
  - កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសំណើរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើខ្លឹមសារនៃសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពី កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ប៊ុន ហុន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនៅទីស្តីការក្រសួងមហាផ្ទៃ
  - ដឹកនាំ ប្រជុំត្រួតពិនិត្យការងារ ដើម្បីរៀបចំកម្មវិធីយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណេត ឆ្នាំ២០២៦ ក្រោមប្រធានបទ "ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ" នៅសាលប្រជុំសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃសាលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង
  - ដឹកនាំ ក្រុមការងារអង្គការ មេត្រីអន្តរជាតិ (AIM) ចុះសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈប្រើប្រាស់ គ្រឿងឧបភោគបរិភោគ ជាកញ្ចប់ជំនួយសង្គ្រោះបន្ទាន់របស់អង្គការ មេត្រីអន្តរជាតិ (AIM) ចែកជូនជនភៀសសឹក ចំនួន ២២៣គ្រួសារ (ក្នុងនោះមានយោធិន ២នាក់ គ្រួសារយោធិន ៣គ្រួសារ គ្រួសារមានក្មេងតូច ៥គ្រួសារ និងជនពិការ ២នាក់) កញ្ចប់សម្រាប់ក្មេងតូចៗចែកជូនបានចំនួន ២៨៤នាក់ និងព្រះសង្ឃចំនួន ៦៩អង្គ នៅវត្តប្រាសាទសែនជ័យ ហៅវត្តភ្នំព្រះទេវៈ ស្ថិតក្នុងភូមិរវៀងតាទុំ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងវីរៈកងទ័ពដែលបានសម្រាកព្យាបាលនៅមន្ទីរពេទ្យយោធភូមិភាគទី៤ ចំនួន ១៧នាក់ ស្ថិតក្នុងក្រុងសៀមរាប ខេត្តសៀមរាប។

- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ,ជ,ប,ជ៖ លិខិតចេញ (១៥ច្បាប់) លិខិតចូល (២០ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(១០ច្បាប់) លិខិតចូល (៣៤ច្បាប់) ៥៤

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមសិក្ខាសាលាពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំង ជាមួយដៃគូ ឆ្នាំ២០២៦ ក្រោមអធិបតីភាព ឯកឧត្តម **តេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ សមាសភាពចូលរួមពី ឯកឧត្តម លោកជំទាវ តំណាង គ.ជ.ប.ជ ស.អ.យ ក្រសួងការងារ ក្រសួងកិច្ចការនារី ក្រសួងការបរទេស បណ្ឌិតសភាភូមិន្ទ យុត្តិធម៌ អគ្គស្នងការនគរបាលជាតិ SOMTC កម្ពុជា ACWC កម្ពុជា ផ្នែកសិទ្ធិស្ត្រី និងកុមារ AICHR កម្ពុជា សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និងអង្គការមិនមែនរដ្ឋាភិបាល ជាតិ អន្តរជាតិ ចំនួន ៣០នាក់ ស្រី១៤នាក់ នៅសាលប្រជុំសណ្ឋាគារ សាន់អេនមុន រាជធានីភ្នំពេញ
  - បានសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃន៍ គ.ជ.ប.ជ មានសមាសភាពចូលរួមមកពី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន ៥៦រូប ស្រី ១៧រូប នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួម ជំនួបដឹកនាំដោយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយ តំណាងអង្គការ IJM ប្រចាំតំបន់ ពិភាក្សាការងារដើម្បីបន្តពង្រឹងកិច្ចសហការ ក្នុងភាពជាដៃគូអភិវឌ្ឍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាម ក្របខណ្ឌយុទ្ធសាស្ត្រជាតិ
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យវឌ្ឍនភាពការងាររៀបចំសៀវភៅសទ្ទានុក្រមក្នុងវិស័យសន្តិសុខ ដឹកនាំដោយ នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ ឯក **មនោសែន** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា នៅសាលប្រជុំ នៃបណ្ឌិត្យសភានគរបាលកម្ពុជា។
- **ខេត្តកែប៖** ឯកឧត្តមបណ្ឌិត សោម ពិសិដ្ឋ អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សខេត្ត បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បី គ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តកំពង់ចាម៖**
  - ឯកឧត្តម អ៊ុន ចាន់ដា អភិបាល នៃគណៈអភិបាលខេត្ត បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅ មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
  - លេខាធិការដ្ឋាន គខបជ៖ បានចូលរួមសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍លើការអអនុវត្ត តួនាទី និងភារកិច្ច របស់លេខាធិការដ្ឋានដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ សហការជាមួយអង្គការបេសកកម្មយុត្តិធម៌ អន្តរជាតិ (IJM) នៅខេត្តសៀមរាប មានអ្នកចូលរួម ៣២នាក់ ស្រី២៦នាក់។
- **ខេត្តឧត្តរមានជ័យ៖**
  - បានចូលរួមកម្មវិធីប្រកាស ដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍គ,ជ,ប,ជ
  - បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរ មនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តក្រចេះ៖**
  - លោកជំទាវ **ខាំ សុភាព** អភិបាលរងខេត្ត និងជាប្រធានលេខា ធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញចូលរួមក្នុងកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ "ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ" ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ដែលសហការឧបត្ថម្ភគាំទ្រដោយអង្គការអែបផល (Aple) នៅសាលមហោស្រព ខេត្តក្រចេះ។
  - បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរ មនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន**គណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។

- **ខេត្តតាកែវ៖** បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តកោះកុង៖** បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តកណ្តាល៖** បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តត្បូងឃ្មុំ៖**
  - បានចូលរួមវគ្គបណ្តុះបណ្តាល លើទម្រង់របាយការណ៍ ស្តីពីការផ្តល់សេវាគាំពារជនរងគ្រោះដោយអំពើជួញដូមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលរៀបចំដោយ នាយកដ្ឋានគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយគម្រោង (TRUS) របស់ទីភ្នាក់ងារសហប្រតិ្តការអន្តរជាតិ ប្រទេសជប៉ុន(JICA) ចំនួន ២លើក។
  - បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
  - លោកជំទាវ នី ចាន់ធីតា បានអញ្ជើញចូលរួមក្នុងពិធីដាក់ឱ្យដំណើរការសៀវភៅ ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ,ជ,ប,ជ នៅទីស្តីការក្រសួងមហាផ្ទៃ។
- **ខេត្តសៀមរាប៖**
  - **លេខាធិការដ្ឋាន គ,ខ,ប,ជ ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច** បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យអនុវត្តន៍សាកល្បង ស្តីពីគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្របដែលបានកែសម្រួល បានចំនួន **១លើក** នៅក្នុងខេត្តសៀមរាប។
  - **មន្ទីរទេសចរណ៍ខេត្ត** បានចូលរួមប្រជុំប្រចាំសប្តាស៍តាមប្រព័ន្ធ Zoom ជាមួយក្រសួងមហាផ្ទៃ ដើម្បីតាមដានវឌ្ឍនភាពការងារបង្រ្កាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) បានចំនួន **២លើក**។
  - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ស្រុក បានចូលរួមវគ្គបណ្តុះបណ្តាលលើម៉ូឌុលមេរៀនកម្រិតទី១ នៃវិធីសិក្សាកំលាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ បានចំនួន ១លើក នៅរាជធានី។
- **ខេត្តមណ្ឌលគិរី៖**
  - **អភិបាលរងទទួលបន្ទុក គ.ខ.ប.ជ** បានចូលរួមកម្មវិធីប្រកាស ដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - **ឯឧត្តមអភិបាលខេត្ត និងលោកស្រីអភិបាលរងទទួលបន្ទុក គ.ខ.ប.ជ** បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- **ខេត្តកំពង់ធំ៖**
  - ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី ភារកិច្ច របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត នៅខេត្តសៀមរាប។
  - ចូលរួមវគ្គបណណ្តុះបណ្តាលអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ។

- ខេត្តបាត់ដំបង៖
  - បានចូលរួមកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៤-២០២៨ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- ខេត្តប៉ៃលិន៖
  - បានចូលរួមកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៤-២០២៨ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - បានចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ "រួមគ្នាដើម្បីគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។